**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ឆ្វៀលដីទំហំ ៤៤ ហិកតា ៣៩ អា និង ៩១ សង់ទីអា ស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញពីដែនគម្រមព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ និងផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋដែលកាន់កាប់ជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**មាត្រា១ .-**

ត្រូវបានកាត់ឆ្វៀលដីទំហំ ៤៤ ហិកតា ៣៩ អា និង ៩១ សង់ទីអា ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា២ .-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីទំហំ ៤៤ ហិកតា ៣៩ អា និង ៩១ សង់ទីអា ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជូនឈ្មោះ ជុំ សាវុឌ្ឍ, ញឹម យន់ស្រ៊ីម, ម៉ុក ប៊ុប៊ុនរិទ្ធ, ហ៊ុន ម៉ាណា, ហ៊ុន ម៉ាលី, ប៉ុក ប៉ាន់ និងឈ្មោះ ឆាយ ណាយ ដែលកាន់កាប់ជាក់ស្តែង។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបង្ហាញក្បាលដីទំហំ ៤៤៣ ៩៩១ ម៉ែត្រក្រឡា ស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ជូនឈ្មោះ ជុំ សាវុឌ្ឍ, ញ៉ឹម យន់ស្រ៊ីម ម៉ុក ប៊ូប៊ុនរិទ្ធ, ហ៊ុន ម៉ាណា, ហ៊ុន ម៉ាលី, ប៉ុក ប៊ាន់ និងឈ្មោះឆាយ ណយ ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

(ដែនគម្របព្រៃឈើឆ្នាំ ២០០២)




តារាងនិយាមកាព្រំដីស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២

Projection, UTM, Zone 48N
Datum, WGS, 1984

| ID | E | N |
|---|---|---|
| 1 | 346834.277 | 1171476.338 |
| 2 | 346752.674 | 1171469.920 |
| 3 | 346652.661 | 1171465.158 |
| 4 | 346586.826 | 1171446.709 |
| 5 | 346551.376 | 1171430.026 |
| 6 | 346544.964 | 1171216.365 |
| 7 | 346542.569 | 1171136.521 |
| 8 | 346536.867 | 1171088.311 |
| 9 | 346524.788 | 1171022.220 |
| 10 | 346526.108 | 1170962.792 |
| 11 | 346529.022 | 1170921.467 |
| 12 | 346529.022 | 1170888.870 |
| 13 | 346525.212 | 1170859.660 |
| 14 | 346523.350 | 1170797.094 |
| 15 | 346520.136 | 1170702.736 |
| 16 | 346518.650 | 1170692.443 |
| 17 | 346516.834 | 1170687.073 |
| 18 | 346503.410 | 1170665.138 |
| 19 | 346499.600 | 1170647.993 |
| 20 | 346502.775 | 1170631.483 |
| 21 | 346505.315 | 1170604.813 |
| 22 | 346512.127 | 1170564.988 |
| 23 | 346518.015 | 1170502.578 |
| 24 | 346542.780 | 1170455.587 |
| 25 | 346565.640 | 1170428.282 |
| 26 | 346581.515 | 1170398.437 |
| 27 | 346589.986 | 1170384.209 |
| 28 | 346594.328 | 1170371.702 |
| 29 | 346592.420 | 1170359.867 |
| 30 | 346581.754 | 1170333.874 |
| 31 | 346577.893 | 1170322.039 |
| 32 | 346578.479 | 1170291.073 |
| 33 | 346590.646 | 1169648.309 |
| 34 | 346640.449 | 1169615.593 |
| 35 | 346802.179 | 1169688.034 |
| 36 | 346818.345 | 1170588.733 |
| 37 | 346833.651 | 1171441.460 |